ភាសាខ្មែរ
クメール語

# まんがでわかる 小売業の安全衛生

# ស្វែងយល់តាមរយៈគំនូរជីវចល សុវត្ថិភាពអនាម័យក្នុងវិស័យលក់រាយ




វីដេអូនេះត្រូវបានរៀបរៀងឡើងដើម្បីឲ្យអ្នកធ្វើការនៅកន្លែងការងារតាមផ្សារទំនើប
អាចសិក្សាពីមូលដ្ឋាននៃសុវត្ថិភាពនិងអនាម័យ។


ថ្ងៃនេះយើងរៀនពី សុវត្ថិភាពអនាម័យ នៅក្នុងវិស័យលក់រាយ!
ផ្សារទំនើបជាកន្លែង ដែលយើងប្រើប្រាស់រាល់ថ្ងៃ និងនៅក្បែរខ្លួនយើង។
មែនហើយ!
អ្នកដែលកំពុងធ្វើការនោះ មិនមែនមានតែអ្នក នៅមុខហាងប៉ុណ្ណោះទេ។
នៅមានអ្នកកំពុងធ្វើការ នៅផ្នែកខាងក្រោយទៀត មែនទេ។
តោះ មកមើលស្ថានភាពកើតឡើង នៃគ្រោះថ្នាក់ការងារ។
បាទ/ចាំ!
ចូរមើលមូលហេតុសំខាន់ នៃគ្រោះថ្នាក់ការងារ។
ចំនួនគ្រោះថ្នាក់ការងារដែលបានកើត
1 រអិលដួល 36 %
2 សកម្មភាពផ្ទុយ/ការធ្វើទាំងបង្ខំ 13 %
3 ធ្លាក់/ដួល 11 %
4 គ្រោះថ្នាក់ចរាចរណ៍ 11 %
5 មុត/កកិត 7 %
យោង៖ ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព «ការវិភាគស្ថានភាពកើតឡើងនៃគ្រោះថ្នាក់ការងារឆ្នាំ២០១៨/ពាណិជ្ជកម្ម (ក្នុងចំណោមវិស័យលក់រាយ)» (ខែឧសភា ឆ្នាំ២០១៩)
«រអិលដួល» ច្រើនមែន...។


មែនហើយ។
ភាគច្រើនដួលដោយសាររអិល
ឬជំពប់ជើង។
នៅកន្លែងរៀបចំអាហារ
ពេលឥដ្ឋសើមធ្វើឲ្យងាយរអិល
ដូច្នេះត្រូវប្រយ័ត្ន។
ម្យ៉ាងទៀត ក៏មានករណីរបួសដោយសារ
បុកត្រូវរទេះដឹក ឬរទេះរុញធ្វើឲ្យដួលដែរ។
គ្រោះថ្នាក់មានបង្កប់ខ្លួន
នៅកន្លែងផ្សេងៗជាច្រើន។
ភាគច្រើនមានការ
ទុកដាក់ឡាំងក្រដាស
ផ្តេសផ្តាស
ធ្វើឲ្យបុកត្រូវក៏អាចមានដែរ។


ធ្វើម៉េចទើបអាចការពារ
ការរអិលដួលបាន?
ចំណុចសំខាន់គឺ
ត្រូវពាក់ស្បែកជើងដែលមិនងាយរអិល
និងរៀបចំឲ្យមានសណ្តាប់ធ្នាប់
កុំឲ្យជំពប់ជើង។
Seiri (ការរៀបចំ)
Seiton (ការធ្វើឲ្យមានសណ្តាប់ធ្នាប់)
Seiso (ការសម្អាត)
Seiketsu (ការធ្វើឲ្យស្អាត)
↓
4 S
ការរៀបចំឲ្យមាន
សណ្តាប់ធ្នាប់គ្រប់ពេលលំបាក
មែន។
សំខាន់ឲ្យតែប្រយ័ត្ន
កុំឲ្យដួលទៅបានហើយ មែនទេ?
ហា?
មិនមែនគិតតែពីខ្លួនឯងទេ
ការបង្កើតកន្លែងការងារ
ដែលគ្មានអ្នករអិលដួល
គឺសំខាន់ណាស់!!
បាទ!


បន្ទាប់មកគឺ «សកម្មភាពផ្ទុយ/ការធ្វើទាំងបង្ខំ» ដែលធ្វើឲ្យគ្រិចចង្កេះនិងដៃ។ វាងាយកើតឡើង ពេលលើករបស់ធ្ងន់។
ពិសេសការឈឺចង្កេះ បើធ្លាប់ឈឺម្តងហើយ ងាយនឹងក្លាយជាទម្លាប់ណាស់ ត្រូវប្រយ័ត្ន។
ប្រសិនបើរងរបួសធ្ងន់មិនអាចធ្វើការបាន ធ្វើឲ្យគ្រួសារបារម្ភផង ហើយផ្នែកសេដ្ឋកិច្ចក៏លំបាកដែរ...។
ដូច្នេះហើយ ចាំបាច់ត្រូវប្រយ័ត្ន កុំឲ្យមានរបួស។
ការ«ធ្លាក់/ដួល» ងាយកើតឡើងនៅពេល យកទំនិញដាក់នៅក្នុងហាង។
ចាំបាច់ត្រូវយល់ដឹងពីរបៀបប្រើ ជើងទ្រសម្រាប់ជាន់ និងជណ្តើរឲ្យបានត្រឹមត្រូវ។


ការ«មុត/កកិត»ក៏មានច្រើនដែរ មែនទេ?
ឧទាហរណ៍ ពេលយកទំនិញចេញពីឡាំង
អាចនឹងមុតដៃដោយសារកាំបិតកាត់ ឬឡាំងក្រដាសដូច្នេះពេលប្រើកាំបិត ត្រូវប្រយ័ត្ន។
គួរឲ្យខ្លាច...។
តោះ
カチッ……
ガーッ
おおっ
ទៅកន្លែងដាក់ស្តែង
1
ពិនិត្យមើល!

# ករណីទី១


ថ្ងៃចាប់ផ្ដើមដាក់លក់ដំបូងផង ភ្លៀងតាំងពីព្រឹកទៀត...
គួរឲ្យស្អប់មែន។
ザァアアア
パタン
បាតស្បែកជើងនេះ សឹកជិតអស់ហើយ ត្រូវឆាប់ដូរហើយ ទើបបាន។
ガチャ
きゅっ
តែមើលទៅដូចមិនទាន់អីទេ...។
ថ្ងៃនេះមាន ទំនិញច្រើនមែន។
ណៃ
ប្រញាប់ជួយយកឡាំងក្រដាសនោះ មកផងបានទេ?
おーい！
お水
បាទ!


つるっ
អូយ!
អត់អីទេ!?
ឥដ្ឋបាន សើម...។


អ អត់អីទេ!
នៅទីនេះមិនអីទេ ឯងទៅយកទំនិញចេញដាក់នៅកន្លែងលក់ទៅ។
បាទ ខ្ញុំទៅហើយ!
タッ
អា៎ ស្បែកជើងសឹកបាត...។
ゴロゴロ
タタタ
キイッ
អូយ!
ガシャーンッ


ណែ៎ អត់អីទេឬ?
អ អត់ អត់អីទេ។
イテテ...
ヌッ
はぁーーーッ
ううう...
សុំទោស...
ជាបឋម មើលស្បែកជើងនោះ
បាតស្បែកជើងសឹកងាយនឹងរអិលណាស់។
ឥឡូវទៅដូរស្បែកជើងភ្លាម។
ខ្ញុំនឹងដូរភ្លាម...។


ពិសេសថ្ងៃដែលមានភ្លៀងធ្លាក់
ឥដ្ឋងាយរអិលខ្លាំង
ត្រូវប្រុងប្រយ័ត្ន។
ពេលឥដ្ឋសើម
ត្រូវយកប្រដាប់ជូតមកជូតសិន
ទើបធ្វើការទៀត។
ខ្ញុំនឹងប្រយ័ត្ន។
មួយទៀត ក្នុងហាងយើង
ពេលចេញចូលតាមទ្វាររុញ
ត្រូវដើរប្រកាន់ឆ្វេង ហើយរុញយឺតៗ
នេះជាវិន័យដឹងទេ?
ទោះប្រញាប់យ៉ាងណា
ក៏មិនត្រូវរត់ដែរ។
មែនហើយ...។
នៅខាងក្រោយហាង
មានមនុស្សជាច្រើន
សុទ្ធតែរវល់។
ត្រូវទុកដាក់ឧបករណ៍
និងផលិតផល
នៅកន្លែងដែលបានកំណត់។
នេះជាកន្លែងដែល
អ្នកទាំងអស់ប្រើប្រាស់
ដូច្នេះត្រូវប្រតិបត្តិតាម4S។


បាទ...។
しょぼーん
កុំខូចចិត្តចឹងពេកមើល។
ការគោរពវិន័យ
គឺដើម្បីរក្សាសុវត្ថិភាព
ឲ្យអ្នកធ្វើការទាំងអស់។
លើកក្រោយពេលប្រជុំពេលព្រឹកខ្ញុំនឹង
លើកឡើងទៀត
យើងត្រូវប្រយ័ត្នទាំងអស់គ្នា។
សិស្សច្បង...
ជាមនុស្សល្អមែន...!
うるっ
ខ្ញុំនឹងប្រឹងប្រែង...!
スーパーYAMADA
នឹងហើយ
ខំប្រឹងឡើង។

# ករណីទី២


DRUG STORE
くすり
សុំានឹងការងារ
បណ្ដើរៗហើយ។
សុំទោស។
ចាំ។
មានរបស់
សម្រាប់ប្តូរដាក់
ក្នុងដបនេះទេ?
あら
ないわ
ចាំ!
សូមរង់ចាំបន្តិច
ខ្ញុំទៅឆែកមើលសិន!!


បងប្រធាន
សាប៊ូសម្រាប់
ប្តូរដាក់ដប
មាននៅកន្លែងណាដែរ?
អត់ឃើញមាននៅលើធ្នើរទេ?
ខ្ញុំទៅមើលភ្លាម
សុំចាំបន្តិច។
កុំរត់នៅក្នុង
ហាងអីណា។
អរគុណ។
អធ្យាស្រ័យ
ចំពោះការឲ្យរង់ចាំ!
ឃើញហើយ!
ល្អ ខ្ញុំនឹងយក
ដោយខ្លួនឯង។
ប៉ុន្តែដូចយកមិនដល់ទេ។
មានអីទ្រជើងទេ...
អូ!
ガシャ


នៅសល់...
តែបន្តិចទៀត...!
សុំទោសដែលមកយឺត... អត់អីទេឬ!?
អត់អីទេ... នៅសល់បន្តិចទៀត...។
អីយ៉ាស់!


ឱ!
ドサ
ドサ
...អ្នកទាំងពីរ អត់អីទេឬ?
សូម អធ្យាស្រ័យ ចំពោះការឲ្យ រង់ចាំ...។
អត់អីទេ។ នេះជារបស់សម្រាប់ប្តូរ...។


STAFF ONLY
ធ្វើការងារជាមួយនឹងធ្នើរខ្ពស់
សូមប្រើជណ្ដើរ
ឲ្យបានត្រឹមត្រូវ។
ពេលប្រើ
ត្រូវជ្រើសរើសជណ្ដើរ
ដែលមានកម្ពស់
ត្រឹមត្រូវ
ហើយកុំខ្លាចលំបាក
ត្រូវដាក់លើ
ទីតាំងត្រឹមត្រូវ។
អញ្ចឹងមែនហើយ...។
មិនត្រូវឡើងលើ
កាំខ្ពស់ជាងគេទេ
ត្រូវឈរ
នៅលើកាំទី២
រាប់ពីលើចុះ។
NG
OK


ゴチャァ
ហើយសូម
ចាប់អារម្មណ៍
ដល់ការរៀបចំផង។
4Sគឺសំខាន់ណាស់។
មែនហើយ...។
សូមអរគុណ។
ពេលចាប់ផ្ដើមសុំគឺគ្រោះថ្នាក់បំផុត។
...ចាំ!

# ករណីទី៣



HOME CENTER
ថ្ងៃនេះពិតជាក្ដៅមែន។
ឮថាសីតុណ្ហភាពខ្ពស់បំផុតគឺ៣៧អង្សារ។
ចឹងមែនហើយ។
ត្រូវបន្ថែមជាតិទឹកនិងជាតិអំបិលឲ្យបានញឹក។
បាទ។
ក្នុងស្រោមដៃក៏បែកញើសឡើងចូក។
ដោះចេញបន្តិចសិន។
ណែ៎ ទំនិញមកហើយ តោះជញ្ជូនចូល។
បាទ!




ល្អ ខ្ញុំនឹងជញ្ជូនឡាំងក្រដាសចេញពីឡានដឹកទំនិញ។ ផលិតផលនេះអស់ស្តុកហើយឯងឆាប់ហែកឡាំងយកទៅ។
ដឹងហើយ។
ポタッ
ポタッ
មានដំបូលមែនតែក្ដៅឡើងចង់ខ្សោះខ្លួនហើយ...។
ណែ៎ មើលទៅឯងដូចមិនស្រួលខ្លួនសោះ អត់អីទេឬ?
គ្រាន់តែវាងវិលមុខបន្តិច អត់អីទេ។
ស្ដាប់ទៅដូចអាការៈឡើងកម្ដៅខ្លួនហើយ។ គួរបន្ថែមជាតិទឹកនិងជាតិអំបិល ហើយសម្រាកនៅកន្លែងត្រជាក់បន្តិចទៅ...។


ពិបាកក្នុងខ្លួនបន្តិចមែន
តែត្រូវប្រញាប់។
スッ
ទេ
មិនអីទេ!
ម៉េចបានជា
មិនពាក់ស្រោមដៃ
អញ្ចឹង...?
くらっ
អូយ!!!
អត់អីទេឬ?


មើលទៅរបួស
ដូចជាមិនសូវជ្រៅខ្លាំងទេ...។
ទៅសម្រាកនៅបន្ទប់បន្តិចទៅ។
ホッ
សុំទោស...។
休憩室
បន្ទប់សម្រាក
របួសដូចជា
មិនមានអីធ្ងន់ធ្ងរទេ។
លែងអីហើយ។
លើកនេះអត់អី
ពិតជាប្រសើរណាស់...
ពេលមិនស្រួលខ្លួនមិនត្រូវធ្វើទាំងបង្ខំទេ
ដំបូងត្រូវរាយការណ៍សិន។
ក្ដៅខ្លាំង ហើយមាន
ជាតិសំណើមខ្លាំងដូចថ្ងៃនេះ
ងាយនឹងបង្កឲ្យកើតអាការៈ
ឡើងកម្ដៅខ្លួនណាស់។


ត្រូវបន្ថែមជាតិទឹក និងជាតិអំបិលឲ្យបានញឹក!
ត្រូវសម្រាកនៅក្នុងបន្ទប់ដែលត្រជាក់ជាប្រចាំ!
ពេលមានអារម្មណ៍មិនស្រួលខ្លួន ត្រូវរាយការណ៍ភ្លាម!
MINERAL WATER
ទាំងនេះគឺជាវិន័យដាច់ខាត។
បាទ!
មែនហើយ កាំបិតកាត់គឺជាឧបករណ៍តែងតែប្រើនៅក្បែរខ្លួន ចាំបាច់ត្រូវប្រយ័ត្នពេលប្រើ។
ដាក់ផ្លែកាំបិតចេញតែបន្តិចបានហើយ។
ត្រូវប្រយ័ត្នទីតាំងដៃ។
កុំឲ្យមានឥរិយាបទធ្វើទាំងបង្ខំ ហើយត្រូវប្រើយឺតៗ។
ចូរគិតថានេះជាមូលដ្ឋានគ្រឹះ។


មានកាំបិតកាត់សម្រាប់ប្រើជាមួយការកាត់ឡាំងក្រដាស។
ប្រភេទមួលខ្ចៅ ត្រូវមួលខ្ចៅឲ្យជាប់នៅពេលប្រើ។
ហើយស្រោមដៃនោះគឺមិនមែនសម្រាប់តែការពាររអិលទេ
វាអាចការពារដៃផងដែរ។ មិនត្រូវដោះចេញតាមចិត្តឡើយ។
ពិតមែនហើយ...។
ដើម្បីខ្លួនឯងនិងគ្រួសារ ត្រូវប្រុងប្រយ័ត្នចំពោះសុវត្ថិភាព!
បាទ!




# ចំណុចគួរប្រុងប្រយ័ត្នក្នុងវិស័យលក់រាយ

## 1 ចូរប្រុងប្រយ័ត្នចំពោះឥដ្ឋសើម និងប្រឡាក់ខ្លាញ់




ទឹកនិងខ្លាញ់ងាយធ្វើឲ្យរអិល ដូច្នេះត្រូវពាក់ស្បែកជើង
ដែលមិនងាយរអិល និងយកចិត្តទុកដាក់ចំពោះ4S។

## 2 ចូរប្រុងប្រយ័ត្ន កុំឲ្យធ្លាក់ពីជណ្តើរ




សូមប្រើជើងទ្រសម្រាប់ជាន់ និងជណ្តើរឲ្យបានត្រឹមត្រូវ។

## 3 ចូរប្រុងប្រយ័ត្នពេលធ្វើការងារ ដែលប្រើកាំបិតកាត់




សូមកុំដាក់ដៃជើងនៅមុខកាំបិតកាត់។

## 4 ធ្វើការនៅកន្លែងក្តៅ ត្រូវប្រុងប្រយ័ត្ន។




ត្រូវសម្រាកនៅកន្លែងត្រជាក់ជាប្រចាំ
ហើយបំពេញជាតិទឹក/ជាតិអំបិល។

ព័ត៌មានលម្អិតសូមមើល«ស្វែងយល់តាមរយៈគំនូរជីវចលមូលដ្ឋាននៃការបង្ការគ្រោះថ្នាក់ការងារ និងសុវត្ថិភាពអនាម័យ(សម្ភារៈអប់រំរូប)»មូលដ្ឋាននៃការ




វិស័យលក់រាយ

# ចូរប្រុងប្រយ័ត្នចំណុចទាំងនេះ!
# ព័ត៌មានជំនួយដើម្បីសុវត្ថិភាព និងសុខភាព!



**1** | ប្រយ័ត្នបុកត្រូវទ្វាររុញសងខាង
នៅពេលបិទបើក!



**2** | ប្រើឥរិយាបទត្រឹមត្រូវ
ពេលលើកទំនិញធ្ងន់




**3** | ចូរយកចិត្តទុកដាក់នឹង
សុត្ថិភាពរបស់ភ្ញៀវផង





ស្វែងយល់តាមរយៈរូបភាព

ស្វែងយល់ពីហានិភ័យបង្កប់ក្នុងកន្លែងធ្វើការ!

# ហ្វឹកហាត់ស្មារតីដឹងមុនពីហានិភ័យ(KYT)

## Q ចូរគិតថាហានិភ័យមាននៅកន្លែងណាខ្លះ!




## A នេះជាចំណុចហានិភ័យ!




1. ការអូសរទេះរុញ និងរទេះដឹកទំនិញពីក្រោយ។



2. មិនទុកឡាំងក្រដាសនៅលើឥដ្ឋ (4S) ។



3. លើកឡើងដោយបន្ទន់ជង្គង់។



ចូរគិតថាមានចំណុចហានិភ័យផ្សេងទៀតដែរឬទេ។

ស្វែងយល់តាមរយៈគំនូរជីវចល

# សុវត្ថិភាពអនាម័យក្នុងវិស័យលក់រាយ

ចេញផ្សាយខែមីនា ឆ្នាំ២០២១

ចេញផ្សាយដោយ៖ ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព

រៀបចំដោយ៖ Mizuho Information & Research Institute, Inc.

សហការដោយ៖ ក្រុមការងាររៀបរៀងសម្ភារៈអប់រំស្តីពីសុវត្ថិភាពពាក់ព័ន្ធនឹងវិស័យលក់រាយ

ផលិតដោយ៖ Sideranch Inc.

厚生労働省
Ministry of Health, Labour and Welfare


កន្លែងទំនាក់ទំនងពាក់ព័ន្ធនឹងឯកសារនេះ

ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព
មន្ទីរស្តង់ដារការងារ
ផ្នែកសុវត្ថិភាពនិងអនាម័យ
ការិយាល័យសុវត្ថិភាព